# សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សំដៅទៅលើសិទ្ធិនៅកន្លែងធ្វើការ សិទ្ធិសន្តិសុខសង្គម សិទ្ធិមានគ្រួសារ និងសិទ្ធិចូលរួមក្នុងជីវភាពវប្បធម៌ក៏ដូចជាសិទ្ធិទទួលបានលំនៅឋាន ស្បៀងអាហារ ទឹក ការថែទាំសុខភាព និងការអប់រំ។

## សិទ្ធិសេដ្ឋកិច្ចសំខាន់ៗ

សិទ្ធិទទួលបានល័ក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាព និងអនាម័យ (មាត្រា ២ កថា ខណ្ឌ (ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌)

សិទ្ធិមិនបង្ខំឲ្យធ្វើការទាំងបង្ខំ (មាត្រា ១០ នៃអនុសញ្ញាស្តីពីការលុបបំបាត់ពលកម្មដោយបង្ខំនៃអង្គការពលកម្មអន្តរជាតិ)

សិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី (មាត្រា ៤៤ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)

សិទ្ធិមានការងារធ្វើ និងសេរីភាពជ្រើសរើសការងារ (មាត្រា ៦ កថាខណ្ឌ (ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច

សិទ្ធិបង្កើត និងចូលរួមជាសហជីពឯករាជ្យ បង្កើតសហព័ន្ធ ឬសហព័ន្ធសហជីព (មាត្រា ៨ កថាខណ្ឌ ក.ខ.គ និងឃ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌)

សិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់សម្រាប់ខ្លួន រួមមានចំណីអាហារ សំលៀកបំពាក់ និងទីលំនៅគ្រប់គ្រាន់ (មាត្រា១១ កថាខណ្ឌ (ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌)

សិទ្ធិទទួលបាននូវលក្ខខណ្ឌការងារត្រឹមត្រូវ (មាត្រា ៧ កថាខណ្ឌ ក.ខ.គ និងឃ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌)

សិទ្ធិធ្វើបាតុកម្មដោយសន្តិវិធី (មាត្រា ៣៧ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)



# សិទ្ធិសង្គមកិច្ចសំខាន់ៗ



សិទ្ធិដើម្បីទទួលបានលំនៅឋានសមរម្យ និងការការពារការបណ្តេញចេញដោយបង្ខំ (មាត្រា ១១ កថាខណ្ឌទី១ (ក និង ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌)

ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូបមានកម្រិតសុខភាព ទាំងខាងរាងកាយ និងខាងស្មារតីខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន (មាត្រា ១២ កថាខណ្ឌទី១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌)





កិច្ចគាំពារ និងការជួយគាំទ្រដល់គ្រួសារ (មាត្រា ១០ កថាខណ្ឌទី១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌)

សិទ្ធិទទួលបានការអប់រំរួមទាំងបឋមជាកាតព្វកិច្ច និងដោយឥតបង់ថ្លៃ (មាត្រា ១៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌)





សិទ្ធិដើរហើរ (មាត្រា ៤០ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)

សិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខ (មាត្រា ៣២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)





# សិទ្ធិវប្បធម៌សំខាន់ៗ



សិទ្ធិចូលរួមក្នុងជីវភាពវប្បធម៌ (មាត្រា ១៥ កថាខណ្ឌ (ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌)



ការអប់រំត្រូវធ្វើឲ្យមនុស្សគ្រប់រូប អាចដើរតួនាទីមានប្រយោជន៍ក្នុងសង្គមសេរី លើកស្ទួយ ការយោគយល់ ការអត់ឱន (មាត្រា ១៣ កថាខណ្ឌទី១នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌)



សិទ្ធិទទួលបានផលប្រយោជន៍ពីភាពជឿនលឿននៃវិទ្យាសាស្ត្រ និងការអភិវឌ្ឍ (មាត្រា ១៥ កថាខណ្ឌ (ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌)



សិទ្ធិទទួលបានកម្មសិទ្ធិលើកម្មសិទ្ធិបញ្ញាផ្ទាល់ខ្លួន និងការបង្កើតថ្មី (មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌)



សិទ្ធិមិនមានការបង្ខិតបង្ខំឲ្យរស់នៅលាយឡំគ្នា ឬរំលាយវប្បធម៌របស់ពួកគាត់ (មាត្រា ៨ កថាខណ្ឌ (ក) នៃសេចក្តីប្រកាសរបស់ អ.ស.ប ស្តីពីសិទ្ធិជនជាតិដើមភាគតិច)



សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការថែរក្សា និងពង្រឹងស្ថាប័នវប្បធម៌ (មាត្រា ៥ នៃសេចក្តី ប្រកាសរបស់ អ.ស.ប ស្តីពីសិទ្ធិជនជាតិដើមភាគតិច)

# ច្បាប់ពាក់ព័ន្ធផ្សេងៗ





## ច្បាប់កម្ពុជា

១ ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិឆ្នាំ១៩៩៦

- ច្បាប់នេះមានគោលបំណងការពារលើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពរបស់ប្រជាជន

២ ច្បាប់ការងារឆ្នាំ១៩៩៧

- ច្បាប់នេះមានគោលបំណងអនុម័តឲ្យស្មើភាពគ្នាចំពោះច្បាប់សម្រាប់និយោជិតទូទាំងប្រទេសកម្ពុជា

៣ ច្បាប់ភូមិបាលឆ្នាំ២០០១

- លម្អិតអំពីសិទ្ធិនៃម្ចាស់កម្មសិទ្ធិករ

៤ ច្បាប់ព្រៃឈើឆ្នាំ២០០២

- ពន្យល់អំពីគោលការណ៍ថែរក្សាសម្បត្តិធនធានព្រៃឈើនៅកម្ពុជាឲ្យមាននិរន្តរភាព

៥ ច្បាប់ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

- ក្រមនេះកំណត់អំពីគោលការណ៍នៃការធានាសេចក្ដីថ្លៃថ្នូររបស់បុគ្គល ភាពស្មើភាពគ្នារបស់បុរស នារី និងសិទ្ធិលើទ្រព្យសម្បត្តិ

៦ ច្បាប់ស្ដីពីការគ្រប់គ្រងធនធានទឹកនៅកម្ពុជាឆ្នាំ២០០៧

- ច្បាប់នេះមានគោលបំណងជម្រុញឲ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព

## ច្បាប់អន្តរជាតិ

១ អនុសញ្ញាស្ដីពីការការពារនិងការលើកកម្ពស់ភាពចម្រុះបែបនៃវប្បធម៌បញ្ចេញមតិ (អង្គការសិក្សាវិទ្យាសាស្ត្រអប់រំ និងវប្បធម៌នៃអង្គការសហប្រជាជាតិ)

- ការការពារនិងលើកម្ពស់ភាពចម្រុះបែបនៃវប្បធម៌បញ្ចេញមតិ

២ អនុសញ្ញាស្ដីពីការលុបបំបាត់ពលកម្មដោយបង្ខំ (អង្គការពលកម្មអន្តរជាតិ)

- ការលុបបំបាត់ទាំងស្រុងជាបន្ទាន់នៃពលកម្មដោយបង្ខំ ឬដោយខាន់តែបាន

៣ អនុសញ្ញាស្ដីពីសិទ្ធិជនពិការ(អង្គការសហប្រជាជាតិ)

- ការពារនិងលើកកម្ពស់ការរីករាយពេញចិត្តសិទ្ធិមនុស្សរបស់ជនពិការ

៤ សេចក្ដីប្រកាសអំពីសិទ្ធិជនជាតិដើមភាពតិច (អង្គការសហប្រជាជាតិ)

- សង្កត់ធ្ងន់លើសិទ្ធិពលរដ្ឋ សិទ្ធិវប្បធម៌ និងសិទ្ធិសេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច

៥ សេចក្ដីប្រកាសអំពីសិទ្ធិជនជាតិដើមភាពតិច (អង្គការសហប្រជាជាតិ)

- តម្រូវឲ្យរដ្ឋអនុម័តគោលនយោបាយថ្នាក់ជាតិក្នុងគោលបំណងលុបបំបាត់ចោលនូវរាល់ទម្រង់នៃការរើសអើង

សម្រាប់ព័ត៌មានបន្ថែមសូមមើលនៅក្នុងគេហទំព័រធុរកិច្ច
និង សិទ្ធិមនុស្សរបស់ ម.ស.ម.ក តាមរយៈ:
http://business.sithi.org

ផលិតដោយ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ឧបត្ថម្ភដោយ

European Union

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

តុលា ២០១៨

CC BY NC SA

CCHRCambodia CCHRCambodia EU.Cambodia OHCHR_Cambodia OHCHRCambodia